**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០០៤/១៩ ក.ប/ស.ជ.ណ.ព.ក

# សេចក្តីជូនដំណឹង

យោងសារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៩ ស្តីពីការចាត់វិធានការថែរក្សាទឹកទុក របស់រាជរដ្ឋាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដល់ម្ចាស់ និងនាយកសហគ្រាស គ្រឹះស្ថាន ជាពិសេសរោងចក្រ សហគ្រាសផ្នែកវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើងទាំងអស់ ត្រូវអនុវត្តឱ្យបានហ្មត់ចត់នូវវិធានការដូចខាងក្រោម៖

១- ត្រូវរក្សាទឹកទុកឱ្យបានគ្រប់គ្រាន់ ដើម្បីធានាដល់ការប្រើប្រាស់ជាប្រចាំនៅក្នុងសហគ្រាស គ្រឹះស្ថាន

២- ត្រូវផ្តល់ទឹកស្អាតសម្រាប់បរិភោគឱ្យបានគ្រប់គ្រាន់ដល់កម្មករនិយោជិត ស្របតាមប្រកាសលេខ ០៥៤ ស្តីពីការផ្តល់ភេសជ្ជៈអនាម័យ

៣- ត្រូវដាក់ឱ្យមានឧបករណ៍វាស់ស្ទង់កំដៅ (សីតុណ្ហមាត្រ) នៅកន្លែងធ្វើការ ដើម្បីងាយស្រួលក្នុងការតាមដានការវិវត្តនៃកំដៅ

៤- ត្រូវត្រួតពិនិត្យ ថែទាំជាប្រចាំ និងបើកឱ្យដំណើរការប្រព័ន្ធបញ្ចេញបញ្ចូលខ្យល់ នៅតាមអគារផលិតកម្មទាំងអស់ឱ្យបានយ៉ាងហោចមួយម៉ោង មុនពេលអនុញ្ញាតឱ្យកម្មករនិយោជិតចូលបម្រើការងារ ស្របតាមប្រកាសលេខ១២៥ ស្តីពីការបញ្ចេញបញ្ចូលខ្យល់ និងការសំអាតបរិយាកាសក្នុងទីកន្លែងធ្វើការ

៥- ត្រូវបើកបង្អួច ទ្វារទាំងអស់ ឬបន្ថែមកង្ហារបញ្ចូលខ្យល់ក្នុងអគារផលិតកម្ម

៦- ត្រូវរៀបចំឱ្យមានប្រព័ន្ធស្រោចទឹកនៅលើដំបូលអគារផលិតកម្ម ឱ្យបានយ៉ាងហោចពីរដងក្នុងមួយថ្ងៃ ឬបន្ថែមសំណាញ់នៅលើដំបូលអគារផលិតកម្មដើម្បីកាត់បន្ថយកំដៅ

៧- ត្រូវរៀបចំទុកដាក់សម្ភារ និងវត្ថុធាតុដើមឱ្យមានសណ្តាប់ធ្នាប់ និងសុវត្ថិភាព កុំឱ្យបាំងប្រភពខ្យល់ចេញចូល ផ្លូវចេញចូល និងទ្វារអាសន្ននៅក្នុងអគារផលិតកម្ម

៨- ត្រូវរក្សាទុកវត្ថុធាតុដើម និងកំទេចក្រណាត់ដាច់ដោយឡែក និងឆ្ងាយពីអគារផលិតកម្ម ឬក្នុងឃ្លាំងសហគ្រាស គ្រឹះស្ថាន ដើម្បីកុំឱ្យសាយភាយក្លិនចូលក្នុងបុរីការងាររបស់កម្មករនិយោជិត

៩- ត្រូវត្រួតពិនិត្យ និងថែទាំជាប្រចាំនូវប្រព័ន្ធបង្ការអគ្គិភ័យ និងសម្ភារការពាររួម នៅក្នុងអគារនៃសហគ្រាស គ្រឹះស្ថាន ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសដោយធានាថា ប្រព័ន្ធ និងឧបករណ៍ទាំងនោះអាចដំណើរការបាននៅពេលមានអាសន្នកើតឡើង ព្រមទាំងអនុវត្តតាមការណែនាំ របស់ក្រុមអធិការកិច្ចការងារ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

១០-ត្រូវរៀបចំឱ្យមានប្លង់សម្រាប់ជម្លៀសខ្លួន សញ្ញាការសុខភាព និងសុវត្ថិភាពការងារ និងការអប់រំបណ្តុះបណ្តាលកម្មករនិយោជិត ស្របតាមប្រកាសលេខ ១៧៦ ស្តីពីការអប់រំអនាម័យ និងបច្ចេកទេសសន្តិសុខការងារដល់កម្មករនិយោជិត ប្រតិភូបុគ្គលិក និងសហជីព

១១-ចំពោះសហគ្រាស គ្រឹះស្ថាន ដែលមានប្រើប្រាស់សារធាតុងាយឆាបឆេះ ត្រូវរៀបចំឱ្យមានប្រព័ន្ធឆ្លើយតបគ្រាអាសន្ន និងរក្សាទុកដាក់សារធាតុទាំងនោះ ឱ្យដាច់ដោយឡែកពីគ្នា និងដាច់ឆ្ងាយពីអគារផលិតកម្ម។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ និង នាយកសហគ្រាស គ្រឹះស្ថានទាំងអស់ នឹងអនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់។

ថ្ងៃ សុក្រ ១៣កើត ខែ បុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- បញ្ជាការឯកភាពក្រុមអធិការកិច្ចការងារ
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានការងារ
- នាយកដ្ឋានអធិការកិច្ចការងារ
- នាយកដ្ឋានពេទ្យការងារ
- គ្រប់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
  "ដើម្បីផ្សព្វផ្សាយ និងអនុវត្ត"
- សមាគមនិយោជក
- សហព័ន្ធសហជីព កម្មករនិយោជិត
  "ដើម្បីជ្រាប និងអនុវត្ត"
- ឯកសារ-កាលប្បវត្តិ